អនុក្រឹត្យ
ស្តីពី
ការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិបង្កក
នៃហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិបង្កក នៃហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះកំណត់អំពីការប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិបង្កកដើម្បីអនុញ្ញាតឱ្យបុគ្គលឬអង្គភាពដែលកាន់កាប់ទ្រព្យសម្បត្តិបង្កកអាចប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិបង្កកនោះតាមច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

មាត្រា២ .-

អនុក្រឹត្យនេះមានវិសាលភាពចំពោះការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិបង្កកក្នុងការអនុវត្តច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣ .-

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់នៅក្នុងអនុក្រឹត្យនេះត្រូវបានកំណត់និយមន័យដូចតទៅ៖

១.ចំណាយមូលដ្ឋាន សំដៅដល់ការចំណាយចាំបាច់ដែលកើតឡើងសម្រាប់គោលបំណងណាមួយដូចខាងក្រោម៖

- ថ្លៃម្ហូបអាហារ
- បង់ថ្លៃឈ្នួលឬប្រាតិភោគ
- ថ្លៃថ្នាំពេទ្យឬថ្លៃព្យាបាល
- បង់ពន្ធ
- បង់ធានារ៉ាប់រង
- ការបង់ថ្លៃទឹក ភ្លើង ហ្គាស សំរាម
- ការបង់ថ្លៃឈ្នួលវិជ្ជាជីវៈ
- ការចំណាយសមស្របពាក់ព័ន្ធដល់ការផ្តល់សេវាច្បាប់
- ការចំណាយផ្សេងៗទៀតដែលមិនរំលោភទៅនឹងសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

២.ចំណាយលើការបំពេញកាតព្វកិច្ចតាមកិច្ចសន្យាដែលបានធ្វើមុនការដាក់ទណ្ឌកម្ម សំដៅដល់ការចំណាយចាំបាច់នៃការអនុវត្តកិច្ចសន្យាមុនថ្ងៃដែលទ្រព្យសម្បត្តិរបស់បុគ្គលឬអង្គភាពត្រូវបានបង្កកហើយការបង់ថ្លៃនោះមិនរំលោភទៅលើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

៣.ចំណាយផ្សេងៗដែលទទួលបានការអនុញ្ញាតនិងស្របតាមសេចក្តីសម្រេចចិត្តនានារបស់អង្គការសហប្រជាជាតិ សំដៅដល់ការចំណាយដែលមិនរាប់ចូលក្នុងចំណាយមូលដ្ឋានឬចំណាយលើការបំពេញកាតព្វកិច្ចតាមកិច្ចសន្យាដែលបានធ្វើមុនការដាក់ទណ្ឌកម្មដែលកំណត់ដោយក្រសួងយុត្តិធម៌និងដែលមិនរំលោភលើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនិងដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះ។

ស្ល

ជំពូកទី២
ការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិបង្កក

មាត្រា៤ .-

ត្រូវបានអនុញ្ញាតឱ្យបុគ្គលឬអង្គភាពដែលកាន់កាប់ទ្រព្យសម្បត្តិបង្កកអាចប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិបង្កកនោះតាមសេចក្ដីសម្រេចរបស់តុលាការដើម្បីជានាះ

- ការចំណាយមូលដ្ឋាន
- ការចំណាយលើការបំពេញកាតព្វកិច្ចតាមកិច្ចសន្យាដែលបានធ្វើមុនការដាក់ទណ្ឌកម្ម
- ការចំណាយផ្សេងៗដែលទទួលបានការអនុញ្ញាតនិងស្របតាមសេចក្ដីសម្រេចចិត្តនានារបស់អង្គការសហប្រជាជាតិ។

មាត្រា៥ .-

បុគ្គលឬអង្គភាពដែលកាន់កាប់ទ្រព្យសម្បត្តិបង្កកត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់និង/ឬចាត់ចែងទ្រព្យសម្បត្តិដែលត្រូវបានបង្កកនោះទៅតុលាការដែលបានចេញសេចក្ដីសម្រេចបង្កក។ សេចក្ដីសម្រេចបង្កកត្រូវធ្វើឡើងជាទម្រង់ដីកាសម្រេច។

ជំពូកទី៣
អវសានប្បញ្ញត្តិ

មាត្រា៦ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៧ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៣ កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

SUB-DECREE
ON
THE USE AND MANAGEMENT OF FROZEN PROPERTY FROM THE FINANCING OF PROLIFERATION OF WEAPONS OF MASS DESTRUCTION

Unofficial Translation

KINGDOM OF CAMBODIA
NATION RELIGION KING

ROYAL GOVERNMENT OF CAMBODIA

No. 159 ANK.BK

SUB-DECREE
ON
THE USE AND MANAGEMENT OF FROZEN PROPERTY FROM THE FINANCING OF PROLIFERATION OF WEAPONS OF MASS DESTRUCTION

THE ROYAL GOVERNMENT OF CAMBODIA

- Having seen the Constitution of the Kingdom of Cambodia
- Having seen Royal Decree no. NS/RKT/0918/925 dated 06 September 2018 on the Appointment of the Royal Government of Cambodia
- Having seen Royal Decree no. NS/RKT/0320/421 dated 30 March 2020 on the Appointment and Modification of the Composition of the Royal Government of Cambodia
- Having seen Royal Kram no. NS/RKM/0618/012 dated 28 June 2018 promulgating the Law on the Organization and Functioning of the Council of Ministers
- Having seen Royal Kram no. NS/RKM/0196/18 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Economy and Finance
- Having seen Royal Kram no. NS/RKM/0196/08 dated 24 January 1996 promulgating the Law on the Establishment of the Ministry of Interior
- Having seen Royal Kram no. NS/RKM/0620/019 dated 27 June 2020 promulgating the Law on Combating the Financing of Proliferation of Weapons of Mass Destruction
- As per its necessary requirement

HEREBY DECIDES

CHAPTER 1
GENERAL PROVISIONS

ARTICLE 1.-

This Sub-Decree sets out the use and management of frozen property in order to enable an individual or entity holding the frozen property to use and manage the frozen property pursuant to the Law on Combating the Financing of Proliferation of Weapons of Mass Destruction.

ARTICLE 2.-

This Sub-Decree applies to the use and management of frozen property from the financing of the proliferation of weapons of mass destruction within the Kingdom of Cambodia.

ARTICLE 3.-

The key terms that are used in this Sub-Decree shall be defined as follows:

1. Basic expenditure refers to necessary expenses incurred from any of the following purposes:
    - Meal expense;
    - Payment for rent or lease;
    - Medication or treatment expenses;
    - Payment for taxes;
    - Payment for insurance premium;
    - Payment for water, electricity, gas and garbage collection services;
    - Payment for professional services;
    - Reasonable expenses associated with legal service; and
    - Other expenses that are not in violation of the United Nations Security Council's resolutions.
2. Expenses on performance of contract obligations prior to the imposition of punishment refer to necessary expenses incurred from performance of contract made prior to the frozen property of the individual or entity and such payment is not in violation of the United Nations Security Council's resolutions.
3. Other expenses that are authorized and in compliance with the United Nations Security Council's resolutions refer to expenses that exclude basic expenses or expenses on contract obligations made prior to the imposition of punishment as determined by the Ministry of Justice, and that are not in violation of the United Nations Security Council's resolutions, and that are adopted by United Nations Security Council or its committee.

CHAPTER 2

THE USE AND MANAGEMENT OF FROZEN PROPERTY

ARTICLE 4.-

An individual or entity holding the frozen property shall be authorized to use and manage the frozen property under the court ruling in order to cover:

- Basic expenses;
- Expenses on performance of contract obligations prior to the imposition of punishment;
- Other expenses that are authorized and in compliance with the United Nations' resolutions.

ARTICLE 5.-

An individual or entity holding the frozen property shall request for the use and/or management of the frozen property from the Court that issues the frozen ruling. The frozen ruling shall be made in a form of a court order.

CHAPTER 3
FINAL PROVISIONS

ARTICLE 6.-

Any provisions that contradict this Sub-Decree shall be abrogated.

ARTICLE 7.-

The Minister in charge of the Office of the Council of Ministers, the Minister of Economy and Finance, the Minister of Interior, the Minister of Justice, all Ministers of relevant ministries and institutions shall be responsible for implementing this Sub-Decree within their respective tasks from the date of signature.

Done in Phnom Penh, on the 30th of September 2020

PRIME MINISTER

(Signed and Sealed)

Samdech Akka Moha Sena Padei Techo HUN SEN

CC:
- Ministry of the Royal Palace
- General Secretariat of the Senate
- General Secretariat of the National Assembly
- Cabinet of Samdech Akka Moha Sena Padei Techo PRIME MINISTER
- Cabinet offices of Samdech, Excellency Deputy Prime Ministers
- Individuals as stated in Article 7
- Royal Gazette
- Documentation and Archives